**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ......០៤៤៧......ស.ភ.រ

# សេចក្តីជូនដំណឹង

សាលាភូមិន្ទរដ្ឋបាល សូមជម្រាបជូនដល់បេក្ខជនជាមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និង ព្រះសង្ឃ ដែលត្រូវចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាពសម្រាប់វគ្គបណ្តុះបណ្តាលបន្ត ឆ្នាំ២០១៧ នៅសាលាភូមិន្ទរដ្ឋបាល ជ្រាបថា ការប្រឡងនឹងប្រព្រឹត្តទៅនៅរសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ ចាប់ពីវេលាម៉ោង១៤:៣០ ដល់ម៉ោង ១៦:៣០ នៅសាលាភូមិន្ទរដ្ឋបាល ។

ប្រភេទវិញ្ញាសាសម្រាប់ការប្រឡងត្រួតពិនិត្យសមត្ថភាព ដែលជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំសិក្សា២០១៧ នៅសាលាភូមិន្ទរដ្ឋបាល រួមមាន៖

វិញ្ញាសាប្រឡងដែលមានចម្លើយជ្រើសរើស (MCQ) ៤០ពិន្ទុ ពាក់ព័ន្ធនឹងវិស័យ៖

- មុខងារសាធារណៈ
- រដ្ឋបាលសាធារណៈ និងប្រព័ន្ធនយោបាយ
- សេដ្ឋកិច្ចទូទៅ
- ចំណេះដឹងទូទៅវប្បធម៌ និងសង្គម

បេក្ខជនត្រូវមកដល់សាលាភូមិន្ទរដ្ឋបាលនៅវេលាម៉ោង១៣:៣០រសៀល ព្រមទាំងភ្ជាប់មកជាមួយនូវ ៖

១.អត្តសញ្ញាណបណ្ណមន្ត្រីរាជការស៊ីវិល អត្តសញ្ញាណបណ្ណកងកម្លាំងប្រដាប់អាវុធ ឬ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

២.ប៊ិចពណ៌ខៀវ និង/ឬបន្ទាត់សម្រាប់ប្រើប្រាស់ពេលប្រឡង។

បេក្ខជនមិនត្រូវបានអនុញ្ញាតឱ្យយកឯកសារ ទូរស័ព្ទ ឧបករណ៍អេឡិចត្រូនិកផ្សេងៗ ចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត។សាលាមិនទទួលខុសត្រូវរក្សាទុកនូវឯកសារ ទូរស័ព្ទ និងឧបករណ៍ អេឡិចត្រូនិច គ្រប់ប្រភេទនេះទេ។

ចំពោះបញ្ជីឈ្មោះបេក្ខជនដែលមានសិទ្ធិចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព សាលាភូមិន្ទរដ្ឋបាលនឹងប្រកាសផ្សាយនៅពេលក្រោយតាមរយៈគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល និងក្រសួងមុខងារសាធារណៈ។ បេក្ខជនអាចចូលទៅក្នុងគេហទំព័ររបស់សាលាwww.era.cambodia.gov.kh និងគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ:www.mcs.gov.kh ដើម្បីទទួលព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការប្រឡងនេះ។

សេចក្តីដូចបានជូនដំណឹងខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧

**នាយកសាលា**

**យក់ ប៊ុនណា**

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញឹកថូឡុង (៥៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ និងទូរសារ :(855) 23 215 408 / 023 997 658
អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh